Knowledge&Skills
Building a Future

Victoria
The Place To Be

# ការស្រង់មតិមាតាបិតា

*មតិរបស់មាតាបិតាគឺជាការចង្អុលបង្ហាញដ៏សំខាន់មួយថា តើសាលារៀនកំពុងបំពេញតាមសេចក្តីត្រូវការរបស់សិស្សបានល្អយ៉ាងណាដែរ។ ជារៀងរាល់ឆ្នាំ មាតាបិតាមួយក្រុមដែលគេជ្រើសរើសដោយព្រាវៗ ត្រូវបានសុំឲ្យឆ្លើយទៅនឹងបញ្ជីសំណួរដ៏ខ្លីមួយអំពីសាលារៀនយើងខ្ញុំ។ នៅឆ្នាំនេះ គេបានជ្រើសយកគ្រួសារលោកអ្នក។ គេលាក់ការយ៉ាងសម្ងាត់នូវចម្លើយរបស់លោកអ្នកទៅនឹងការស្រង់មតិនេះ ហើយភាពផ្ទាល់ខ្លួនរបស់លោកអ្នកគឺសំខាន់ណាស់។ សូមកុំសរសេរឈ្មោះលោកអ្នកនៅលើក្រដាសស្រង់មតិនេះ។*

*សេចក្តីបរិយាយតទៅនេះពណ៌នានូវចំណុចនានានៃការសិក្សាអប់រំរបស់កូនលោកអ្នក។ សូមប្រាប់នូវទំហំដែលលោកអ្នកយល់ស្រប ឬ មិនយល់ស្របទៅនឹងសេចក្តីបរិយាយ ដោយគូសព័ទ្ធជុំវិញតួលេខសមស្របនៅតាមកំរិតដូចតទៅនេះ:*

មិនយល់ស្រប ជាខ្លាំង ◄······► យល់ស្រប ជាខ្លាំង

| | | | | | | | |
|---|---|---|---|---|---|---|---|
| កូនខ្ញុំទន្ទឹងរង់ចាំដោយរីករាយក្នុងការរៀនសូត្រដែលកូនខ្ញុំសិក្សានៅសាលារៀន | 1 | 2 | 3 | 4 | 5 | 6 | 7 |
| កូនខ្ញុំចុះសំរុងយ៉ាងល្អជាមួយក្រុមអាយុស្របាលគ្នានៅសាលារៀន | 1 | 2 | 3 | 4 | 5 | 6 | 7 |
| កូនខ្ញុំកំពុងគ្រប់គ្រងយ៉ាងស្ទាត់នូវជំនាញប្រាស្រ័យទាក់ទងក្នុងសង្គម | 1 | 2 | 3 | 4 | 5 | 6 | 7 |
| កូនខ្ញុំរីករាយនឹងការធ្វើកិច្ចការគ្រូដាក់ឲ្យធ្វើនៅផ្ទះ | 1 | 2 | 3 | 4 | 5 | 6 | 7 |
| កូនខ្ញុំមានអារម្មណ៍ទទួលយកដោយសិស្សឯទៀតនៅសាលារៀន | 1 | 2 | 3 | 4 | 5 | 6 | 7 |
| ស្តង់ដារសិក្សាអប់រំនៅសាលារៀននេះ ផ្តល់ការខិតខំខ្លាំងក្លាគ្រប់គ្រាន់សំរាប់កូនខ្ញុំ | 1 | 2 | 3 | 4 | 5 | 6 | 7 |
| កូនខ្ញុំកំពុងបង្កើតជំនាញល្អក្នុងការប្រាស្រ័យទាក់ទងក្នុងសង្គម | 1 | 2 | 3 | 4 | 5 | 6 | 7 |
| កម្មវិធីសិក្សាអប់រំនៅសាលារៀននេះ សមរម្យសំរាប់កូនខ្ញុំ | 1 | 2 | 3 | 4 | 5 | 6 | 7 |
| កូនខ្ញុំទទួលការបង្ហាត់អំពីជំនាញរៀបចំ ដើម្បីជួយកូនខ្ញុំធ្វើកិច្ចការគ្រូដាក់ឲ្យធ្វើនៅផ្ទះ | 1 | 2 | 3 | 4 | 5 | 6 | 7 |
| កូនខ្ញុំចុះសំរុងល្អជាមួយសិស្សឯទៀតនៅសាលារៀន | 1 | 2 | 3 | 4 | 5 | 6 | 7 |
| សាលារៀននេះកំពុងបំពេញតាមសេចក្តីត្រូវការសិក្សាអប់រំរបស់កូនខ្ញុំ | 1 | 2 | 3 | 4 | 5 | 6 | 7 |
| កូនខ្ញុំទន្ទឹងរង់ចាំដោយរីករាយក្នុងការទៅសាលារៀន | 1 | 2 | 3 | 4 | 5 | 6 | 7 |
| កូនខ្ញុំបានទទួលការសម្លុតធ្វើបាបនៅពេលថ្មីៗនេះនៅសាលារៀន | 1 | 2 | 3 | 4 | 5 | 6 | 7 |
| សាលារៀនកូនខ្ញុំមានសកម្មភាពល្អសំរាប់បន្ថែមទៅលើកម្មវិធីសិក្សា | 1 | 2 | 3 | 4 | 5 | 6 | 7 |
| កូនខ្ញុំចង់ទៅសាលារៀនជានិច្ច | 1 | 2 | 3 | 4 | 5 | 6 | 7 |
| កិច្ចការកូនខ្ញុំដែលគ្រូដាក់ឲ្យធ្វើនៅផ្ទះ ជួយកូនខ្ញុំក្នុងការរៀនសូត្ររបស់វា | 1 | 2 | 3 | 4 | 5 | 6 | 7 |
| មុខវិជ្ជាទាំងឡាយដែលបង្រៀននៅសាលារៀននេះ បំពេញតាមសេចក្តីត្រូវការរបស់កូនខ្ញុំ | 1 | 2 | 3 | 4 | 5 | 6 | 7 |
| កូនខ្ញុំរីករាយចំពោះការរៀនសូត្រដែលកូនខ្ញុំសិក្សានៅឯសាលារៀន | 1 | 2 | 3 | 4 | 5 | 6 | 7 |
| សិស្សឯទៀតមានភាពកាចឆ្នាស់ចំពោះកូនខ្ញុំ | 1 | 2 | 3 | 4 | 5 | 6 | 7 |
| សាលារៀននេះផ្តល់សកម្មភាពបន្ថែមផ្សេងៗយ៉ាងសមរម្យពីលើកម្មវិធីសិក្សា | 1 | 2 | 3 | 4 | 5 | 6 | 7 |
| កូនខ្ញុំកំពុងបង្កើតជំនាញប្រាស្រ័យទាក់ទងក្នុងសង្គមដ៏មានតម្លៃ | 1 | 2 | 3 | 4 | 5 | 6 | 7 |
| កូនខ្ញុំបានទទួលការនិយាយលូកលាន់នៅពេលថ្មីៗនេះនៅឯសាលារៀន | 1 | 2 | 3 | 4 | 5 | 6 | 7 |
| ជាសរុប ខ្ញុំពេញចិត្តនឹងការសិក្សាអប់រំដែលកូនខ្ញុំទទួលពីសាលារៀនរបស់វា | 1 | 2 | 3 | 4 | 5 | 6 | 7 |

*សេចក្តីបរិយាយតទៅនេះពណ៌នានូវចំណុចទាំងឡាយនៃសាលារៀនរបស់កូនលោកអ្នក។ សូមប្រាប់នូវទំហំដែលលោកអ្នកយល់ស្រប ឬ មិនយល់ស្របទៅនឹងសេចក្តីបរិយាយ ដោយគូសព័ទ្ធជុំវិញតួលេខសមស្របនៅតាមកំរិតដូចតទៅនេះ:*

មិនយល់ស្រប ជាខ្លាំង ◄······► យល់ស្រប ជាខ្លាំង

| | | | | | | | |
|---|---|---|---|---|---|---|---|
| គ្រូបង្រៀននៅសាលារៀនកូនខ្ញុំប៉ិនប្រសប់ណាស់ក្នុងការធ្វើឲ្យការរៀនសូត្រគឺជាការរីករាយ | 1 | 2 | 3 | 4 | 5 | 6 | 7 |
| គ្រូបង្រៀននៅសាលារៀនកូនខ្ញុំ មានការប្តូរផ្តាច់យ៉ាងខ្លាំងក្លាណាស់ | 1 | 2 | 3 | 4 | 5 | 6 | 7 |
| សិស្សខ្លះបង្កការរំខាននៅក្នុងថ្នាក់រៀន ដោយធ្វើឲ្យកូនខ្ញុំលំបាករៀនសូត្រ | 1 | 2 | 3 | 4 | 5 | 6 | 7 |
| មានការប្រាស្រ័យទាក់ទងទៅវិញទៅមកយ៉ាងល្អ រវាងបុគ្គលិកនិងមាតាបិតានៅសាលារៀនកូនខ្ញុំ | 1 | 2 | 3 | 4 | 5 | 6 | 7 |
| គ្រូបង្រៀននៅសាលារៀនកូនខ្ញុំ មានភាពសាទរខ្លាំងណាស់ | 1 | 2 | 3 | 4 | 5 | 6 | 7 |
| ឥរិយាបថរបស់សិស្សឯទៀត រារាំងដល់ការរៀនសូត្ររបស់កូនខ្ញុំ | 1 | 2 | 3 | 4 | 5 | 6 | 7 |
| សាលារៀននេះមានគោលបំណងជានិច្ចក្នុងការកែលំអគុណភាពសិក្សាអប់រំដែលសាលារៀនផ្តល់ឲ្យ | 1 | 2 | 3 | 4 | 5 | 6 | 7 |
| គ្រូបង្រៀននៅសាលារៀនកូនខ្ញុំ ប៉ិនប្រសប់ណាស់ក្នុងការជំរុញទឹកចិត្តកូនខ្ញុំឲ្យរៀនសូត្រ | 1 | 2 | 3 | 4 | 5 | 6 | 7 |
| គ្រូបង្រៀននៅសាលារៀនកូនខ្ញុំ ចូលចិត្តការបង្រៀនខ្លាំងណាស់ | 1 | 2 | 3 | 4 | 5 | 6 | 7 |
| សាលារៀននេះមានការយល់ដឹងច្បាស់លាស់អំពីចំណុចខ្លាំងនិងចំណុចខ្សោយរបស់ខ្លួន | 1 | 2 | 3 | 4 | 5 | 6 | 7 |
| គ្រូបង្រៀននៅសាលារៀនកូនខ្ញុំ គ្រប់គ្រងឥរិយាបថសិស្សដោយត្រឹមត្រូវ | 1 | 2 | 3 | 4 | 5 | 6 | 7 |
| គ្រូបង្រៀននៅសាលារៀនកូនខ្ញុំ មានមោទនភាពច្រើននៅក្នុងការងាររបស់ខ្លួន | 1 | 2 | 3 | 4 | 5 | 6 | 7 |
| គ្រូបង្រៀននៅសាលារៀននេះមានហេតុផលជំរុញកូនខ្ញុំឲ្យចង់រៀនសូត្រ | 1 | 2 | 3 | 4 | 5 | 6 | 7 |



*សូមបែរទៅទំព័រម្ខាងទៀត*

| | មិនយល់ស្រប ជាខ្លាំង | | | ◄·········► | | | យល់ស្រប ជាខ្លាំង |
|---|---|---|---|---|---|---|---|
| សាលារៀននេះជំរុញទឹកចិត្តមាតាបិតាឲ្យផ្តល់មតិនៅក្នុងការគ្រោងធ្វើផែនការសំរាប់អនាគត | 1 | 2 | 3 | 4 | 5 | 6 | 7 |
| របាយការណ៏របស់សាលារៀនកូនខ្ញុំ មានប្រយោជន៏ណាស់ | 1 | 2 | 3 | 4 | 5 | 6 | 7 |
| ខ្ញុំមានអារម្មណ៏កក់ក្តៅក្នុងការទាក់ទងសាលារៀននេះ បើខ្ញុំមានការបារម្ភណាមួយ | 1 | 2 | 3 | 4 | 5 | 6 | 7 |
| គ្រូបង្រៀនរបស់កូនខ្ញុំ យល់អំពីទស្សនៈរបស់ខ្ញុំ | 1 | 2 | 3 | 4 | 5 | 6 | 7 |
| គ្រូបង្រៀននៅសាលារៀនកូនខ្ញុំ មានភាពស្វាហាប់ណាស់ | 1 | 2 | 3 | 4 | 5 | 6 | 7 |
| សាលារៀននេះជំរុញទឹកចិត្តកូនខ្ញុំឲ្យមានភាពស្វិតស្វាញក្នុងការរៀនសូត្រ នៅពេលមានការលំបាក | 1 | 2 | 3 | 4 | 5 | 6 | 7 |
| គ្រូបង្រៀននៅសាលារៀនកូនខ្ញុំ គ្រប់គ្រងឥរិយាបថសិស្សតាមវិធីមួយដែលរក្សាខ្ជាប់ជានិច្ច | 1 | 2 | 3 | 4 | 5 | 6 | 7 |
| សាលារៀននេះខិតខំកែលំអជានិច្ច | 1 | 2 | 3 | 4 | 5 | 6 | 7 |
| សាលារៀននេះជំរុញទឹកចិត្តមាតាបិតាឲ្យផ្តល់មតិ នៅពេលគ្រោងធ្វើគោលការណ៏ថ្មី | 1 | 2 | 3 | 4 | 5 | 6 | 7 |
| របាយការណ៏របស់កូនខ្ញុំផ្តល់នូវការយល់ដឹងល្អមួយនូវរបៀបដែលកូនខ្ញុំកំពុងរីកចំរើននៅសាលារៀន | 1 | 2 | 3 | 4 | 5 | 6 | 7 |
| គ្រូបង្រៀននៅសាលារៀនកូនខ្ញុំ គ្រប់គ្រងឥរិយាបថសិស្សប្រកបដោយការយល់ចិត្តយល់ថ្លើម | 1 | 2 | 3 | 4 | 5 | 6 | 7 |
| ខ្ញុំមានឱកាសចូលរួមធ្វើផែនការនិងសំរេចលើកិច្ចការទាំងឡាយនៅសាលារៀននេះ បើខ្ញុំមានបំណង | 1 | 2 | 3 | 4 | 5 | 6 | 7 |
| របាយការណ៏របស់កូនខ្ញុំរៀបរាប់អំពីការរីកចំរើនគ្រប់ផ្នែកទាំងអស់របស់កូនខ្ញុំ ដែលខ្ញុំត្រូវការដឹង | 1 | 2 | 3 | 4 | 5 | 6 | 7 |
| ខ្ញុំមានឱកាសផ្តល់មតិឆ្លុះបញ្ចាំងទៅឲ្យសាលារៀនរបស់កូនខ្ញុំ អំពីបញ្ហាទាំងឡាយដែលសំខាន់ចំពោះខ្ញុំ | 1 | 2 | 3 | 4 | 5 | 6 | 7 |
| សាលារៀននេះគិតគូរយ៉ាងម៉ត់ចត់នូវការបារម្ភរបស់មាតាបិតា | 1 | 2 | 3 | 4 | 5 | 6 | 7 |

*ឥឡូវនេះ យើងខ្ញុំចាប់អារម្មណ៏អំពីបទពិសោធន៏ឆ្លងកាត់របស់កូនលោកអ្នកនៅក្នុងការសិក្សាអប់រំរបស់កូនលោកអ្នក (ដូចជាការផ្លាស់ប្តូរសាលារៀន ការចេញពីបឋមសិក្សាទៅមធ្យមសិក្សា ឬពីឆ្នាំមួយទៅឆ្នាំមួយទៀតជាដើម)។ សូមប្រាប់អំពីទំហំដែលលោកអ្នកយល់ស្រប ឬ មិនយល់ស្របទៅនឹងសេចក្តីបរិយាយ ដោយគូសព័ទ្ធជុំវិញតួលេខសមស្រប នៅតាមកំរិតដូចតទៅនេះ:*

| | មិនយល់ស្រប ជាខ្លាំង | | | ◄·········► | | | យល់ស្រប ជាខ្លាំង |
|---|---|---|---|---|---|---|---|
| កូនខ្ញុំត្រៀមខ្លួនយ៉ាងល្អសំរាប់ដំណាក់កាលបន្ទាប់នៅក្នុងការសិក្សាអប់រំរបស់ខ្លួន | 1 | 2 | 3 | 4 | 5 | 6 | 7 |
| កូនខ្ញុំបានទទួលជំនួយយ៉ាងល្អនៅពេលដែលកូនខ្ញុំបានចាប់ផ្តើមវិលទៅសាលារៀនវិញ នៅឆ្នាំនេះ | 1 | 2 | 3 | 4 | 5 | 6 | 7 |
| មុនពេលដំណាច់ឆ្នាំមុន កូនខ្ញុំបានត្រៀមខ្លួនយ៉ាងល្អសំរាប់ឆ្នាំនេះ នៅសាលារៀន | 1 | 2 | 3 | 4 | 5 | 6 | 7 |
| កូនខ្ញុំបានទទួលជំនួយនៅក្នុងការឆ្លងកាត់នៅឯសាលារៀន | 1 | 2 | 3 | 4 | 5 | 6 | 7 |

*បើសិនជាលោកអ្នកមានមតិណាមួយផ្សេងទៀតអំពីសាលារៀននេះ សូមប្រើកន្លែងទំនេរខាងក្រោមនេះ។*

(គេនឹងថតស្កែនប្រអប់ផ្តល់មតិនេះ ហើយគេនឹងផ្តល់ទៅឲ្យសាលារៀនរបស់កូនលោកអ្នកនូវរូបភាពនៃចម្លើយរបស់លោកអ្នក។ គេនឹងមិនតភ្ជាប់ទៅនឹងអត្តសញ្ញាណរបស់កូនលោកអ្នកទេ។ សូមកុំសរសេរនៅខាងក្រៅប្រអប់នេះ; គេនឹងមិនថតស្កែនការសរសេរណាមួយនៅខាងក្រៅប្រអប់នេះទេ ហើយសាលារៀននឹងមិនអានមតិទាំងនោះបានឡើយ។ សូមកុំសរសេរប្រាប់ឈ្មោះរបស់គ្រូបង្រៀន ឬសិស្សទាំងឡាយឡើយ។)

## សូមអរគុណលោកអ្នកចំពោះការបំពេញចម្លើយនៅក្នុងបញ្ជីសំណួរនេះ។

សូមដាក់បញ្ជីសំណួរនេះទៅក្នុងស្រោមសំបុត្រដែលផ្តល់ជូនមកស្រាប់ សរសេរឈ្មោះនិងកំរិតថ្នាក់របស់កូនលោកអ្នកនៅលើគំរបសន្ទះខាងក្រោយនៃស្រោមសំបុត្រនេះ ហើយប្រគល់វាទៅឲ្យសាលារៀនវិញ។ សាលារៀននឹងកត់ត្រាការប្រគល់បញ្ជីសំណួររបស់លោកអ្នក ប៉ុន្តែគេនឹងមិនបើកស្រោមសំបុត្រនេះនៅសាលារៀនទេ ហើយចម្លើយរបស់លោកអ្នកនឹងនៅតែលាក់ការសម្ងាត់ដដែល។